# ផ្នែកសំខាន់នៃស្ថានភាពដំណាំបាយអូតិច/ជីអេម (Biotech/GM Crops) ជាលក្ខណៈពាណិជ្ជកម្ម នៅលើសកលលោក

**រៀបរៀងដោយ ឃ្លីវ ជែមស៍, ស្ថាបនិក និងប្រធាន ISAAA**

អត្ថបទនេះសង្ខេបផ្នែកសំខាន់របស់ដំណាំបាយអូតិចនៅឆ្នាំ២០០៨ ដែលត្រូវបានពិនិត្យឡើងវិញយ៉ាងទូលំទូលាយ នៅក្នុងសេចក្តីសង្ខេបទី៣៩ របស់ISAAA (http://www.isaaa.org)។ ជាលទ្ធផលនៃផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច បរិស្ថាន និងសុខុមាលភាពដែលមានស្ថេរភាព និងរឹងមាំ កសិករក្រីក្រខ្វះធនធាន ខ្នាតតូច និងខ្នាតធំ ក្នុងបញ្ជីមានចំនួន ១៣.៣លាននាក់ បានបន្តដាំដុះយ៉ាងផុសផុលលើផ្ទៃដីជាច្រើនហិកតានូវដំណាំបាយអូតិចនៅឆ្នាំ២០០៨។ ការរីកចំរើនក៏ត្រូវបានធ្វើឡើងទៅលើទីកន្លែងដាំដុះជួរមុខសំខាន់ដទៃជាច្រើនទៀតក្នុងឆ្នាំ២០០៨ នេះផងដែរ ជាមួយនឹងកំណើនគួរកត់សំគាល់នៅក្នុងប្រទេសជាច្រើនដែលដាំដុះដំណាំបាយអូតិចជាលក្ខណៈសកលលោក; ភាពជឿនលឿនច្រើនបង្គួរនៅក្នុងទ្វីបអាហ្វ្រិកដែលការប្រកួតប្រជែងមានភាពទូលំទូលាយបំផុត; មានការកើនឡើងចំពោះការទទួលយកនូវពូជបង្កាត់ដែលទទួលបានទិន្នផលខ្ពស់; និងការណែនាំអោយស្គាល់នូវដំណាំបាយអូតិចថ្មី។ ទាំងនេះគឺជាការអភិវឌ្ឍន៍ចំបងដែលត្រូវបានផ្តល់អោយ ថាតើដំណាំបាយអូតិចចូលរួមចំណែកទៅលើចំនួននៃការប្រកួតប្រជែងចំបង ដែលប្រឈមមុខក្នុងសង្គមសកលលោករួមមានៈ សុវត្ថិភាពចំណីអាហារ ចំណីសត្វ និងពពួកសារធាតុសរសៃ តំលៃអាហារទាបនិរន្តភាព ការកាត់បន្ថយភាពក្រីក្រ និងការអត់ឃ្លាន ហើយនិងការបន្ធូរមួយចំណែកនៃការប្រកួតប្រជែងដែលពាក់ព័ន្ធជាមួយនឹងការផ្លាស់ប្តូរបរិយាកាសសង្គម។

ចំនួននៃប្រទេសដែលដាំដុះដំណាំបាយអូតិចបានកើនឡើងដល់ ២៥ប្រទេស - ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ - ដែលជាវលកថ្មីមួយនៃការអនុម័តទទួលយកដំណាំបាយអូតិច ដែលត្រូវបានចូលរួមចំណែកក្នុងការរីកចំរើនជាលក្ខណៈសកលយ៉ាងធំទូលាយ។

ការរីកចំរើននៅក្នុងទ្វីបអាហ្វ្រិក : ប្រទេសជាច្រើនជាពិសេសប្រទេសអាហ្វ្រិកខាងត្បូងបានបង្កើនពីមួយនៅឆ្នាំ២០០៧ ទៅដល់បីនៅឆ្នាំ២០០៨ ជាមួយនឹងប្រទេសបឺរគីណាហ្វាសូ (ដំណាំកម្បាស) និងប្រទេសអេស៊្សីប (ដំណាំពោត) ដែលដាំដុះដំណាំបាយអូតិចសំរាប់ជាលើកដំបូង។

ប្រទេសបូលីវី (សណ្តែកសៀងពូជ RR) បានក្លាយជាប្រទេសទី៩ នៅទ្វីបអាមេរិកឡាទីន ក្នុងការអនុម័តទទួលយកដំណាំបាយអូតិចទៅធ្វើការដាំដុះ។

ផ្ទៃដីដាំដុះដំណាំបាយអូតិចនៅលើសកលលោកបានបន្តការកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ២០០៨ សំរាប់ឆ្នាំទី១៣នៃការដាំដុះ : ការកើនឡើងចំនួន ១០.៧លានហិកតា (៩.៤%) ដែលអាចឈានទៅដល់ ១២៥លានហិកតា ឬក៏ជាក់ច្បាស់ជាងនេះគឺ ១៦៦លានហិកតានៃពូជបង្កាត់ដែលទទួលបានទិន្នផលខ្ពស់ ដែលស្មើទៅនឹង ២២លានហិកតានៃការកើនឡើង (១៥%)។ ការកើនឡើងផ្ទៃដីដាំដុះចំនួន ៧៤ដង ចាប់តាំងពីឆ្នាំ១៩៩៦ ធ្វើអោយដំណាំបាយអូតិចក្លាយជាបច្ចេកវិទ្យាដំណាំដែលត្រូវបានអនុម័តទទួលយកយ៉ាងឆាប់រហ័ស។

សំរាប់ជាលើកដំបូងនៅឆ្នាំ២០០៨ ផ្ទៃដីដាំដុះរួមនៃដំណាំបាយអូតិច សំរាប់កំឡុងឆ្នាំ ១៩៩៦ ដល់ ២០០៨ មានលើសពី ២០០០លានអេឃើ (៨០០លានហិកតា) វាចំណាយពេលវេលា ១០ឆ្នាំ សំរាប់ផ្ទៃដីមួយពាន់លានអេឃើជាលើកទី១ នៅឆ្នាំ២០០៥ ប៉ុន្តែចំណាយរយ:ពេល ៣ឆ្នាំប៉ុណ្ណោះ សំរាប់ផ្ទៃដីមួយពាន់លានអេឃើជាលើកទី២ នៅឆ្នាំ២០០៨។ គួរកត់សំគាល់ថាមានចំនួន ២៥ប្រទេស ដែលកំពុងដាំដុះដំណាំបាយអូតិច ដែលក្នុងនោះ ១៥ប្រទេស ជាប្រទេសកំពុងអភិវឌ្ឍន៏ ទល់នឹង ១០ប្រទេស ជាប្រទេសឧស្សាហកម្ម។

ដំណាំបាយអូតិចថ្មីឈ្មោះ សូហ្គឺប៊ីតពូជ RR (sugar beet) ត្រូវបានធ្វើពាណិជ្ជកម្មជាលើកដំបូងនៅប្រទេសអាមេរិក និងកាណាដា នៅឆ្នាំ២០០៨។

ប្រទេសចំនួនប្រាំរួមមាន : ប្រទេសអេស៊្សីប បឺរគីណាហ្វាសូ បូលីវី ប្រេស៊ីល និងអូស្ត្រាលី បានណែនាំអោយស្គាល់ជាលើកដំបូង នូវដំណាំបាយអូតិចដែលបានត្រូវពួកគេធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសដទៃទៀត។

ពូជបង្កាត់ដែលទទួលបានទិន្នផលខ្ពស់ជាលក្ខណ:ពិសេសនៃដំណាំបាយអូតិចដែលមានសំខាន់ និងរីកចំរើន។ ប្រទេសចំនួនដប់បានដាំដុះប្រហែល ២៧លានហិកតា នៃពូជបង្កាត់ដែលទទួលបានទិន្នផលខ្ពស់នៅឆ្នាំ២០០៨ ហើយមានកំនើន ២៣% ពួកវាលូតលាស់លឿនជាងពូជទោលធម្មតា។

នៅឆ្នាំ២០០៨ ចំនួនកសិករដាំដំណាំបាយអូតិចត្រូវបានកើនឡើងពី ១.៣លាននាក់ រហូតដល់ ១៣.៣លាននាក់ នៅក្នុងប្រទេសចំនួន ២៥ លើសកលលោក - គួរកត់សំគាល់ថា មានកសិករចំនួន ១២.៣លាននាក់ ឬក៏ ៩០% ជាកសិករក្រីក្រខ្វះធនធាន និងកសិករខ្នាតតូចដែលស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

ដំណាំបាយអូតិចបានធ្វើអោយប្រសើរទៅលើប្រាក់ចំណូល និងគុណភាពនៃជីវិតរបស់កសិករក្រីក្រខ្វះធនធាន និងកសិករខ្នាតតូច ក៏ដូចជាគ្រួសាររបស់ពួកគេ ហើយនិងបានចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ពួកគេ - ករណីសិក្សាជាច្រើនត្រូវបានយោងនៅក្នុងសេចក្តីសង្ខេបទី៣៩ សំរាប់ប្រទេសឥណ្ឌា ចិន អាហ្វ្រិកខាងត្បូង និងហ្វីលីពីន។

ប្រទេសកំពុងអភិវឌ្ឍន៍ចំបងចំនួន ៥ រួមមាន : ប្រទេសចិន ឥណ្ឌា អាហ្សង់ទីន ប្រេស៊ីល និងអាហ្វ្រិកខាងត្បូង ដែលមានចំនួនប្រជាជនសរុប ២.៦ពាន់លាននាក់ កំពុងប្រើប្រាស់ភាពជាអ្នកដឹកនាំជាមួយនឹងដំណាំបាយអូតិច និងកំពុងជំរុញក្នុងការទទួលយកទៅអនុវត្តជាលក្ខណៈសកលលោក - ផលប្រយោជន៍ពីដំណាំបាយអូតិចកំពុងជំរុញទៅមុខនូវឆន្ទៈផ្នែកនយោបាយដ៏រឹងមាំ និងការបណ្តាក់ទុនថ្មីច្រើនបង្គួរ នៅក្នុងដំណាំបាយអូតិច ក្នុងប្រទេសជាច្រើនក្នុងចំណោមប្រទេសនាំមុខទាំងនេះ។

គួរកត់សំគាល់ទៅលើប្រទេសសហគមន៍អឺរ៉ុបដែលមានចំនួនទាំងអស់ប្រាំពីរ ដែលកំពុងដាំដុះដំណាំពោតប៊ីធី បានបង្កើននូវផ្ទៃដីដាំដុះរបស់ពួកគេ ដែលជាលទ្ធផលមានការកើនឡើងជាទូទៅចំនួន ២១% ដែលមានផ្ទៃដីដាំដុះលើសពី ១០៧ ០០០ហិកតា នាឆ្នាំ២០០៨ កន្លងមកនេះ។

ការចូលរួមចំណែកយ៉ាងសម្បើមចំពោះដំណាំបាយអូតិច ដើម្បីធានានិរន្តភាពគឺត្រូវបានពិនិត្យមើលឡើងវិញដូចតទៅ : ១-ចូលរួមចំណែកចំពោះសុវត្ថិភាពចំណីអាហារ ចំណីសត្វ និងពពួកសារធាតុសរសៃ ដែលរាប់បញ្ចូលចំណីអាហារមានគ្រប់គ្រាន់បន្ថែមទៀត (តំលៃអាហារទាប); ២-អភិរក្សជីវៈចំរុះ; ៣-ចូលរួមចំណែកចំពោះការកាត់បន្ថយភាពក្រីក្រ និងការអត់ឃ្លាន; ៤-កាត់បន្ថយផលប៉ះពាល់បរិស្ថានដែលកើតចេញពីការធ្វើកសិកម្ម; ៥-ជួយបន្ធូរនូវការផ្លាស់ប្តូរបរិយាកាសសង្គម និងកាត់បន្ថយនូវឧស្ម័នភាយចេញពីផ្ទះកញ្ចក់; ៦-ចូលរួមចំណែកចំពោះការផលិតជីវៈប្រេងឥន្ធនៈដែលមានប្រសិទ្ធភាពផ្នែកតំលៃបន្ថែមទៀត; ៧-ចូលរួមចំណែកទទួលផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលមាននិរន្តភាពដែលមានតំលៃ ៤៤ពាន់លានដុល្លា ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០៧។ ជាសង្ខេបចំណុចលើកឡើងដែលប្រមូលមកទាំងប្រាំពីរនេះគឺមានការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធានានិរន្តភាព និងសក្តានុពលសំរាប់អនាគតដែលមានលក្ខណៈធំមហិមា។

ក្នុងចំណោមការទទួលចំណូលផ្នែកសេដ្ឋកិច្ចដែលមានតំលៃ ៤៤ពាន់លានដុល្លា ក្នុងកំឡុងពេល១៩៩៦ ដល់២០០៧ មាន ៤៤% បានទទួលពីចំណូលទិន្នផលជាចំបង និង ៥៦% បានទទួលពីការកាត់បន្ថយនៅក្នុងការចំណាយក្នុងផលិតកម្ម (រួមមាន ៣៥៩ ០០០តោន ដែលបានមកពីការសន្សំនៅក្នុងថ្នាំសំលាប់សត្វចង្រៃ); ចំណូលផលិតកម្មមានចំនួន ១៤១ លានតោន មានការទាមទារ ៤៣លានហិកតាបន្ថែម ដែលដំណាំបាយអូតិចមិនត្រូវបានលាតត្រដាង - បច្ចេកវិទ្យាសន្សំដី។

នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ពឹងផ្អែកលើកសិកម្ម និងកែទំរង់ ដំណាំបាយអូតិចគឺជាយន្តការនៃការលូតលាស់ផ្នែកសេដ្ឋកិច្ចជនបទ ដែលអាចចូលរួមចំណែកយ៉ាងខ្លាំងក្លាជាលំដាប់ទៅលើការលូតលាស់ផ្នែកសេដ្ឋកិច្ចជាតិ។

ច្រើនជាងពាក់កណ្តាល (៥៥%) នៃចំនួនប្រជាជនពិភពលោក រស់នៅក្នុងប្រទេសចំនួន ២៥ ដែលបានដាំដុះ ១២៥លានហិកតានូវដំណាំបាយអូតិចនៅឆ្នាំ២០០៨ សមាមាត្រទៅនឹង ៨% ក្នុងចំណោម ១.៥ពាន់លានហិកតានៃផ្ទៃដីដាំដំណាំសរុបនៅលើពិភពលោក។ នៅឆ្នាំ២០០៧ ដំណាំបាយអូតិចសន្សំ ១៤.២ពាន់លានគីឡូក្រាមនៃឧស្ម័នកាបូនិច ដែលសមមូលទៅនឹងចំនួនរថយន្តដែលមានតិចជាង ៦.៣ លាន។

មានសេចក្តីត្រូវការបន្ទាន់សំរាប់ប្រព័ន្ធកំណត់ប្រសិទ្ធិភាពតំលៃ/ពេលវេលាសមស្រប សំរាប់ដំណាំបាយអូតិចដែលឆ្លើយតប ប៉ុន្តែមិនស្មុគស្មាញ និងមានគ្រប់គ្រាន់សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍។

ប្រទេសចំនួន ២៥ បានធ្វើការអនុម័តលើការដាំដុះដំណាំបាយអូតិច និងប្រទេសចំនួន ៣០ ផ្សេងទៀតបានធ្វើការអនុម័តលើការនាំចូលនូវផលិតផលបាយអូតិច សំរាប់ការប្រើប្រាស់ជាចំណីអាហារ និងចំណីសត្វ ដែលមានចំនួនសរុបទាំងអស់ ៥៥ប្រទេសដែលចូលរួមក្នុងការអនុម័ត។

នៅឆ្នាំ២០០៨ តំលៃទីផ្សារដំណាំបាយអូតិចនៅលើពិភពលោក មាន ៧.៥ពាន់លានដុល្លា ជាមួយនឹងតំលៃជាគោលមាន ៥០ពាន់លានដុល្លាសំរាប់កំឡុងពេល១៩៩៦ ដល់២០០៨។

សេចក្តសង្ឃឹមទៅអនាគត : ទស្សនវិស័យសំរាប់រយៈពេល៧ឆ្នាំ ដែលនៅសល់នៃទសវត្សទី២ ក្នុងការធ្វើពាណិជ្ជកម្មដំណាំបាយអូតិច (ឆ្នាំ២០០៦ ដល់ឆ្នាំ២០១៥ ឃើញថាអាចនឹងមានជោគជ័យ) ការព្យាករណ៍របស់ ISAAA នៅឆ្នាំ២០០៥ ដែលថាចំនួនប្រទេសដាំដុះដំណាំបាយអូតិច ផ្ទៃដីដាំដុះ និងកសិករដែលទទួលផល អាចកើនទ្វេដងរវាងឆ្នាំ២០០៦ និងឆ្នាំ២០១៥ គឺស្ថិតនៅលើផ្លូវត្រឹមត្រូវ។ ដំណាំស្រូវជាដំណាំមួយ និងធន់នឹងភាពរាំងស្ងួតជាពូជមួយត្រូវបានរំពឹងទុកដែលសំខាន់ក្រៃលែងសំរាប់ការលូតលាស់នាពេលអនាគត។ សេចក្តីសង្ខេបរួមបញ្ចូលលក្ខណៈពិសេសទៅលើពោតបាយអូតិចដែលធន់នឹងភាពរាំងស្ងួត ដែលត្រូវបានរំពឹងទុកចំពោះ ការដែលត្រូវបានធ្វើពាណិជ្ជកម្មនៅសហរដ្ឋអាមេរិក នៅឆ្នាំ២០១២ ឬក៏លឿនជាងនេះ និងនៅទ្វីបអាហ្វ្រិកអនុតំបន់សាហារ៉ា នៅឆ្នាំ២០១៧។

ព័ត៌មានបន្ថែមត្រូវបានផ្តល់ជូននៅក្នុងសេចក្តីសង្ខេបទី៣៩ ស្តីអំពីផ្នែកសំខាន់នៃស្ថានភាពដំណាំបាយអូតិច/ជីអេម (Biotech/ GM Crops) ជាលក្ខណៈពាណិជ្ជកម្មនៅលើសកលលោក : ឆ្នាំ២០០៨ រៀបរៀងដោយ ឃ្លីវ ជែមស។ សំរាប់ព័ត៌មានផ្សេងទៀត សូមបើកមើលវេបសាយ http://www.isaaa.org ឬក៏ទាក់ទង ISAAA SEAsiaCenter តាមលេខទូរស័ព្ទ +63-49-536-7216 ឬអ៊ីម៉ែលទៅកាន់ info@isaaa.org ។